# ដំណាំត្រសក់ចំណារ



រៀបរៀងដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## I. ស្ថានភាពទូទៅ

ដំណាំត្រសក់ត្រូវបានគេជឿជាក់ថា មានប្រភពនៅប្រទេសឥណ្ឌាជាង ៣០០០ឆ្នាំ ក្រោយមកក៏រីករាលដាល ទៅទ្វីបអឺរ៉ុបយ៉ាងលឿន ជាពិសេសនៅប្រទេសអេស៊ីប ប្រទេសក្រិច និងរ៉ូម៉ាំង ។ ប៉ុន្តែនៅសតវត្សទី ១៦-១៧ បានរីកចំរើនខ្លាំងនៅទ្វីបអាមេរិក ។ តាមស្ថិតិពីអង្គការស្បៀង និងកសិកម្មពិភពលោក FAO ដំណាំនេះត្រូវ បានដាំដុះលើផ្ទៃដីប្រមាណ ៨០០.០០០-៨៥០.០០០ ហិកតា ហើយបរិមាណផលសរុបប្រចាំឆ្នាំប្រមាណ ១០.១៥០.០០០ - ១០.២០០.០០០ តោន ។ ក្រោយមកនៅឆ្នាំ ១៩៨៨ ប្រទេសចិនជាអ្នកនាំមុខគេដោយបានដាំលើផ្ទៃដី២៤០.០០០ហិកតា បរិមាណផលសរុប ៣.៧ លានតោន ប្រទេសឥណ្ឌូនេស៊ីមានផ្ទៃដី ៤០.០០០ ហិកតា និងប្រទេសថៃលំដាប់លេខ៣គឺមានផ្ទៃដី១២.០០០ហិកតាហើយបរិមាណផលសរុប ១៤៣.០០០តោន ។ ដំណាំប្រភេទនេះ គេចាត់បញ្ចូលទៅក្នុង ដំណាំត្រូវការអាកាសធាតុក្តៅមធ្យមចន្លោះ ១៨-៣០ °c ។

- ត្រសក់ចំណារស្ថិតក្នុងលំដាប់ Cucurbits គ្រួសារ Cucurbitaceae ឈ្មោះវិទ្យាសាស្ត្រ Cucumis sativus ឈ្មោះធម្មតាគឺ Cucurnber ។ គេចែកចេញជាពីរប្រភេទ គឺប្រភេទសំបករលោង និង សំបកគ្រើម ។ វាជាប្រភពនៃវីតាមីន និងសារធាតុរ៉ែ ផ្សេងៗជាច្រើនដូចជា ទឹក ៩៦.៣ក្រាម ប្រូតេអ៊ីន ០.៤៤ក្រាម ប្រេង០.៥ក្រាម កាល់ស្យូម ១០មីល្លីក្រាម ផូស្វ័រ ២៥ មីល្លីក្រាម ដែក ១.៥ មីល្លីក្រាម វីតាមីនសេ ៧ មីល្លីក្រាម និងផ្តែកថាមពល ១៣ គីឡូកាឡូរី ទម្ងន់ផ្លែខ្ចី ១០០ ក្រាម ។

## II. បច្ចេកទេសដាំដុះ

-ដើម្បីទទួលបានទិន្នផលពីការដាំដុះដំណាំត្រសក់ក៏ដូចដំណាំឯទៀតដែរ ត្រូវមានការងារច្រើនដែលត្រូវ អនុវត្តន៍ដូចតទៅ :

១- ការជ្រើសរើសពូជ

-ការជ្រើសរើសពូជជាកត្តាសំខាន់បំផុតនៅក្នុងការដាំដុះ ព្រោះពូជមានលក្ខណៈផ្សេងៗពីគ្នា ហើយត្រូវបានចែកចេញជា ៣ប្រភេទ ដូចតទៅ:

– ពូជស្រាល Early variety ពូជនេះមានអាយុកាលលូតលាស់ខ្លីចំនួន ៣៥-៤០ថ្ងៃ ។ ភាគច្រើនគឺផ្លែល្អិតតូចៗ ជាចង្កោមៗមានបន្លាច្រើនជួរតាមបណ្តោយនៃផ្លែ ទទឹងផ្លែមិនលើស ១.៥សម ប្រវែងជាមធ្យម ៨-១០ សម ។ ស្លឹកល្អិតដើមតូចផ្កាឈ្មោលច្រើនតាមថ្នាំងនៃដើម ហើយមានរោមក្រាស់លើផ្ទៃស្លឹក

និងដើម គ្រាប់តូចល្អិតស្រួចៗហើយខ្លីទម្ងន់ ១០០ គ្រាប់មានចំនួន ២,៥-៤ក្រាមប្រភេទនេះគេឲ្យឈ្មោះ ត្រសក់ បន្លា ឬត្រសក់ជ្រក់ Pickling Cucumber ។

- ពូជកណ្តាល Medium Variety ពូជនេះមាន អាយុកាលលូតលាស់មធ្យម ពី ៤០-៥០ថ្ងៃ ។ ផ្លែភាគ ច្រើនមានពណ៌បៃតងស្រាលផ្នែកខាងគូទមានពណ៌ លឿងខ្ចី ផ្លែច្រើនរាយៗ មិនចង្កោម ទទឹងផ្លែមាន ប្រវែង៣-៤សម បណ្តោយផ្លែប្រវែងពី ១០-១៣ សម រាងរបស់ផ្លែវាធំកណ្តាលតូចក្បាល និងកន្ទុយ ពូជប្រភេទ នេះកសិករភាគច្រើនដាំនៅតាមសួនបន្លែ មិនមានលក្ខណៈទ្រង់ទ្រាយផលិតកម្មធំៗឡើយ ព្រោះ ទិន្នផលរាប់ពី ៦-៨តោន១ហត ។ លក្ខណៈសំគាល់គឺ ស្លឹកធំស្តើងរាងមូល រោមខ្លីៗមានពណ៌បៃតងធម្មតា គ្រាប់ សំប៉ែតធំខ្លី Smooth Skintyes ។

- ពូជធ្ងន់ Late Variety ពូជនេះមានអាយុកាល លូតលាស់ពី ៥០-៦០ថ្ងៃ ។ ផ្លែរបស់វាទ្រវែងមានពណ៌ បៃតងចាស់ប្រមាណ ២,៣នៃប្រវែងផ្លែ ។ មានថ្នាំង រង្វើលបែកមែកមធ្យម ស្លឹកធំក្រាស់ហើយស្រួចមានរោម រឹង ទទឹងផ្លែជាមធ្យម៣៥សម ប្រវែងជាមធ្យម១២-២០ សម រូបសណ្ឋាននៃគ្រាប់ទ្រវែងស្រួចកំប៉ោងកណ្តាល ដាំភាគច្រើននៅខេត្តកណ្តាល កំពង់ឆ្នាំងនិងកំពង់ចាម ។ ត្រសក់មិនមែនជាដំណាំប្រកាន់រដូវឡើយប៉ុន្តែពូជត្រសក់ ក្រោយពីប្រមូលផលគ្រាប់ហើយត្រូវការសំរាករយៈ ពេលពី៤-៦ ខែ ទើបអាចដុះបាន ។ លក្ខណៈពិសេស មួយទៀតគឺបច្ចុប្បន្នមានពូជ ២ប្រភេទ គឺពូជគ្មាន ជំនាន់OPV អាចដាំ ហើយទុកពូជបានប៉ុន្តែពូជបង្កាត់ Hybrid $F_1$ មិនអាចទុកពូជបានឡើយ ។ សេចក្តីត្រូវ ការពូជសម្រាប់ដាំលើផ្ទៃដី ១ហត គឺ ៣,៥-៥គក្រ អាស្រ័យទៅតាមភាគរយដំណុះនិងចន្លោះគុម្ពនៃការ ដាំ ។

## ២- ការជ្រើសរើសរដូវ

- សម្រាប់លក្ខខណ្ឌប្រទេសកម្ពុជា ដំណាំត្រសក់ មិនមែនជាដំណាំដែលប្រកាន់រដូវឡើយ វាអាចដុះលូត លាស់បានចន្លោះសីតុណ្ហភាពពី ២០-៣០ °c ។ ប៉ុន្តែ រដូវសមស្របបំផុតគឺនៅចុងរដូវវស្សាចាប់ពីខែតុលា



ដល់ ខែ កុម្ភៈព្រោះក្នុងកំឡុងពេលនេះ ត្រសក់អាច លូតលាស់ល្អទិន្នផលខ្ពស់ បណ្តាលមកពី កត្តាសីតុណ្ហ ភាពចុះទាប សំណើមបរិយាកាសខ្ពស់ភ្លៀងមិនអូស បន្លាយ សីតុណ្ហភាពដីប្រែប្រួលទាប រយៈពេលពន្លឺ ថ្ងៃមានកំរិតសមស្រប ។ ប៉ុន្តែត្រសក់ជួបកត្តាលំបាក ជាច្រើន ចាប់ពីខែមីនា ដល់ ខែឧសភា គឺសត្វល្អិត ជំងឺបំផ្លាញច្រើន បណ្តាលមកពី លក្ខខណ្ឌអាកាស ធាតុមិនសមស្រប ធ្វើឲ្យត្រសក់ទិន្នផលទាប។ តែ នៅរដូវវស្សាវិញចាប់ពីខែ មិថុនា ដលខែ កញ្ញា ត្រសក់ ច្រើនជួបជំងឺ បំផ្លាញច្រើនជាងសត្វល្អិត បណ្តាលមក ពីសំណើមដី និងសីតុណ្ហភាពដីប្រែប្រួល ។

## ៣- ការជ្រើសរើស និងរៀបចំដី

- ដំណាំនេះអាចលូតលាស់បានល្អក្នុងរយៈ ពេលកំពស់មិនលើសពី ១០០០ ម ធៀបនិងផ្ទៃដី សមុទ្រ ។

-ការជ្រើសរើសដី: ត្រសក់ត្រូវការដីមានជី ជាតិគ្រប់គ្រាន់ សំបូរទៅដោយសារធាតុចិញ្ចឹម និង បន្ទុកខ្យល់គ្រប់គ្រាន់សម្រាប់វាគឺប្រភេទដីល្បាប់មាត់ ស្ទឹង បឹង ទន្លេ និងដីល្បាយខ្សាច់ ដែលមានដាំសម្រាប់ ដុះស្រូវទាប់លើ) ជ្រៅស្រស់ទឹកល្អ មិនដក់ទឹកក្រោយ ពេលភ្លៀងធ្លាក់ កាលណាទឹកដក់លើសពី ៤ម៉ោងឡើង ទៅធ្វើឲ្យត្រសក់ងាយកើតជំងឺទុំស្លឹក ។ ក្រៅពីនោះ វាអាចលូតលាស់ល្អដែរនៅលើប្រភេទដីក្រហម និង ដីខ្មៅក្នុងតំបន់ខ្ពង់រាប ប៉ុន្តែ ដីឥដ្ឋ ឬដីដូ ត្រសក់លូត លាស់មិនល្អឡើយ ។ កាលណាដីដែលធ្លាប់ដាំដំណាំ ប្រភេទអំបូរត្រសក់ Cucurbita ceae ជាច្រើនលើរួច

មកគេត្រូវបន្ថែមជីលាមកសត្វជាច្រើនតោនក្នុង ១ហិកតា ចន្លោះពី ២០-៣០តោន ។ ដីដែល ឆ្លើយតបខ្លាំងមាន pH ៦,៥-៧,៥ កាលណា pH ទាបជាង ៤ ផ្អាកការដាំត្រសក់រយៈពេល ១-២ឆ្នាំ ត្រូវដាំ ដំណាំអំបូរសណ្តែក ដើម្បីកែលំអដី ។

- ការរៀបចំដី : ត្រូវរាស់ប្រមូលយកស្មៅ និងដំណាំផ្សេងៗពីរដូវមុនចេញ ភ្ជួរហាលដីលើកទី១ឲ្យជ្រៅត្រឡប់ស្រទាប់ដី ពីក្រោមឡើងលើ និងហាលដីឲ្យបានច្រើនសប្តាហ៍ ក្នុងគោលបំណងបន្ថយនូវភ្នាក់ងារចម្លងជំងឺ និងសត្វល្អិត ព្រមទាំងឲ្យស្មៅចង្រៃងាប់ ជាពិសេសគឺប្តូរទម្រង់ដី និងពង្រាយជីជាតិ។ការភ្ជួរ និងត្រូវ ធ្វើឲ្យបាន ២-៣ លើកមុននឹងលើករងដាំដុះ។ កាលលើករងសម្រាប់ដាំ គឺអាស្រ័យទៅវិធីដាំ និងជីជាតិរបស់ដី។ កាលណាដាំដោយដោតចំណារបញ្ឈរទទឹងរងត្រូវមានប្រវែង ១២០សម កំពស់រង ២៥-៣០សម ។ ប៉ុន្តែបើដាំ ឲ្យវានៅលើដី ទទឹងរងមានប្រវែងពី ៨០-១០០ សម តែការដាំតាមវិធីនេះត្រសក់មានផ្លែចំនួនតិច ទិន្នផលទាប ។ នៅក្នុងលក្ខខណ្ឌអាកាសធាតុក្តៅ ដីរក្សាសំណើមត្រូវគ្របដីមុនពេលដាំ ដើម្បីបន្ថយកំដៅដី ស្មៅ រក្សាសំណើមបានយូរ និងធ្វើឲ្យដីធូរមិនហាប់ កាលណាដីហាប់បណ្តាលឲ្យបន្ទុកខ្យល់ $O_2$ មិនគ្រប់គ្រាន់ចំនួន និងប្រវែងឫសចាក់ បានតិច ។

៤- វិធីសាស្ត្រដាំដុះ

- មុននឹងដាំ ត្រូវយកគ្រាប់ពូជមកដាក់ហាលថ្ងៃឲ្យក្តៅ រយៈពេល ១-២ ម៉ោង បន្ទាប់មកយកទៅ




ត្រាំទឹករយៈពេល៤-៥ម៉ោងបន្ទាប់មកត្រូវលាងសំអាតគ្រាប់ឲ្យស្អាតចំនួន ៣-៤លើកមុនពេលផ្អាប់ត្រាំគ្រាប់ពូជ ។ ការផ្អាប់ត្រូវយកក្រណាត់ជ្រលក់ទឹកឲ្យជោគយកមកខ្ចប់គ្រាប់នោះ ហើយកប់ទៅក្នុងដីសើមៗរយៈ ពេល ១យប់ ។ មុនដាំត្រូវយកគ្រាប់ពូជមកលាយជាមួយ និងថ្នាំសម្លាប់ផ្សិតប្រភេទ Captan Zinneb Mancozeb ក្នុងកំរិត ២% ឬ ១គក្រ គ្រាប់ពូជបរិមាណថ្នាំកន្លះស្លាបព្រាបាយ ច្របល់ឲ្យសព្វមុនយកទៅដាំ ដោយប្រើចន្លោះគុម្ព ២៥សម ចន្លោះជួរ៦០សម ជំរៅ ២-៣ សម ២-៣ គ្រាប់ក្នុងមួយគុម្ពហើយគ្របពីលើដោយកំណាត់ចំបើងខ្លីៗ ឬជីធម្មជាតិពុករលួយល្អពីវិធីនេះគឺដាំឲ្យត្រសក់ឡើងតោងចំណារបញ្ឈរ ប៉ុន្តែការដាំវាលើដី ត្រូវប្រើចន្លោះគុម្ព ៥០សម ៣-៤គ្រាប់ ក្នុងមួយគុម្ព តែគ្របគុម្ពដូចគ្នា ។ ក្រោយពីដាំភ្លាមត្រូវពិនិត្យ មើលសំណើមដី កាលណា ដី ស្ងួតខ្លាំង ត្រូវតែស្រោចទឹកក្រោយដាំហើយដើម្បីឲ្យត្រសក់ដុះស្មើគ្នាងាយថែទាំ ។ ក្រោយពីដាំរយៈពេល ៣-៤ថ្ងៃ ក្នុងលក្ខខណ្ឌអាកាសធាតុពេលថ្ងៃ ៣០ $^{\circ}C$ និងពេលយប់ ១៨-២០ $^{\circ}C$ ធ្វើឲ្យត្រសក់លូតលាស់លឿន ។

៥- របៀបស្រោចស្រព

- ដំណាំត្រសក់ជាប្រភេទដំណាំត្រូវការទឹកជាប្រចាំ ប៉ុន្តែសំណើមដីមិនលើសពី ៥០-៧០ % ឡើង ។ សេចក្តីត្រូវការទឹកចែកចេញជា បីវគ្គ :

- វគ្គលូតលាស់ : ចាប់ពីត្រសក់ដុះ រហូតដល់ត្រសក់បោះដៃ និងមានផ្កាក្រពុំ វាត្រូវការសំណើមដីជាមធ្យមប្រមាណពី ៥០-៦០% ។ របៀបស្រោច ដោយបាញ់ទឹកពីលើ ល្អជាងការស្រោចដោយបញ្ចូលតាមចន្លោះ ជួរ គឺ ១ថ្ងៃម្តង ឬ២ដង ទៅតាមប្រភេទដីនិងអាកាសធាតុ បរិមាណទឹក ក្នុងវគ្គនេះមានប្រមាណពី ១៤០០-១៦០០ ម៣/ហត ។

- វគ្គបន្តពូជ និងផ្លែ : ចាប់ពីត្រសក់មានអាយុពី ១៥ថ្ងៃឡើងទៅវានិងមានផ្កាឈ្មោលចេញតាមថ្នាំង ប៉ុន្តែមិនទាន់រីក វគ្គនេះវាត្រូវការសំណើមដីពី៦០-៧០% គឺជាវគ្គដែលត្រូវការទឹកច្រើនជាងគេ រហូតដល់ត្រសក់មានអាយុ ៣០-៤០ថ្ងៃ ក្រោយដាំ ប៉ុន្តែការស្រោចដោយបញ្ចូលតាមចន្លោះមួយអាទិត្យ ២-៣លើករង



ជាការល្អ ព្រោះការស្រោចដោយបាញ់ទឹកពីលើធ្វើឲ្យប៉ះពាល់ដល់ការបន្តពូជ Cross– Pollinated បរិមាណទឹកសរុប ក្នុងវគ្គនេះមានពី ១៨០០-២០០០ម$^{៣}$ ។

- វគ្គចេញផ្លែ ១០០% (Fruit matarity ) ចាប់ពីការប្រមូលផលបាន ១-២ លើកត្រសក់ត្រូវការសំណើមដីទាបគឺពី ៥០-៦៥% កាលណាការបញ្ចូលទឹកលើសពីនេះ ធ្វើឲ្យត្រសក់ចាប់ប្រែពណ៌ពីបៃតងទៅលឿង ក្នុងការស្រោចទឹក ១-២លើកជាការល្អ បរិមាណទឹកពី ១៤០០-១៦៥០០ ម$^{៣}$ ។

៦- ដកស្មៅនិងជ្រុំជ្រោយដី

- ការជ្រុំជ្រោយដីត្រូវធ្វើឡើង នៅពេលត្រសក់មានសន្លឹកពិតចំនួន ២ គឺនៅពេលទងរបស់វាលូតវែង (១០-១៥ថ្ងៃក្រោយដាំ) ត្រូវជ្រុំបំបែកដីសើៗហើយកៀរយកដីពីបាតរងមកលប់គល់ឲ្យជិតក្នុងករណីដីដែល ដុះស្មៅ ត្រូវដកយកស្មៅចេញមុនជ្រុំជ្រោយដី ។ ចំពោះការដាំដោយគ្រប និងកៅស៊ូខ្មៅ Black plastic mulching មិនចាំបាច់ជ្រុំជ្រោយដីឡើយ ។ ការជ្រុំជ្រោយដីគឺប្រយោជន៍ធ្វើឲ្យដីធូរ ជ្រាបទឹកបានល្អរក្សាសំណើមបានយូរ ធ្វើឲ្យខ្យល់ចេញចូលបានល្អបន្ថយការលូតលាស់របស់ស្មៅ ។

៧- ការដោតចំណារ

- ដំណាំត្រសក់ក៏ដូចដំណាំឯទៀតដែរ វាត្រូវការសារធាតុចិញ្ចឹម ៣យ៉ាងសំខាន់គឺ អាសូត N ផូស្វ័រ P ប៉ូតាស្យូម K និងសារធាតុផ្សេងៗទៀត ដូចជា Ca . S . Fe. Bo ។ល។ប៉ុន្តែសារធាតុទាំងនោះ វាត្រូវការទៅតាម ដំណាក់កាលរបស់វាដូចជា : ដំណាក់កាលលូតលាស់ដើម ស្លឹក វាត្រូវការអាសូតច្រើនជាងគេ បន្ទាប់មកគឺផាត ប៉ូតាស្យូម ប៉ុន្តែផូស្វ័រ វាត្រូវការបន្តិចម្តងៗ ចាប់ពីវគ្គកំណកំណើតផ្កា ដោយបរិមាណក្នុងមួយវដ្តជីវិតក៏តិចជាងគេ (Ranl hawa ១៩៦៨) ដូចនេះ ការប្រើប្រាស់ជីត្រូវដាក់ទៅតាមដំណាក់កាលរបស់វា :

- មុនពេលដាំគេតែងដាក់ជីធម្មជាតិ ឲ្យបានច្រើនពី ១៥-២០តោន ១ហត និងជីគីមីប្រភេទ ១៥ ១៥ ១៥ ចំនួន ១៥០គក្រ ជីទាំងនោះត្រូវដាក់ទៅក្នុងបាតរណ្តៅហើយជ្រុំដីលប់ឲ្យជិតពីលើ ទើបធ្វើការដាំដុះតាម ក្រោយ ។

- ក្រោយពេលដាំរយៈពេល ១០-១៥ថ្ងៃ គេត្រូវយកជីអាសូតសុទ្ធ (អ៊ុយរ៉េ) ចំនួន ២៥-៣០គក្រ មក លាយទឹកស្រោចចំៗគុម្ព បន្ទាប់មកស្រោចទឹកលាងតាមក្រោយ ។

- នៅក្នុងវគ្គត្រសក់ចេញផ្កា ១០០% គេយកជីគីមីប្រភេទ ១៥ ១៥ ១៥ ដដែលចំនួន ១០០គក្រ មក ដាក់តាមចន្លោះគុម្ពហើយលប់ដីឲ្យជិត បន្ទាប់មកស្រោចទឹកឲ្យជោគ ។

III. **ជំងឺនិងសត្វល្អិត** Diseases and Insect

១- អំពីជំងឺផ្សិត

- ត្រសក់រងការបំផ្លាញដោយជំងឺផ្សិតច្រើនប្រភេទ ហើយគ្រប់វគ្គលូតលាស់ វគ្គបន្តពូជ និងវគ្គទុំនៃផ្លែ ។



*ជំងឺរលាកគល់កូនដំណាំ : ដែលឲ្យឈ្មោះថា Damping – Off វាបង្កឡើងដោយ ក្រុមផ្សិត ច្រើន ដូចជា Pythium species, Rhizoctonia solani, Basicola Acremonium species Fusarium equiseti និងប្រភេទ



ផ្សិតជាច្រើនទៀត ។ រោគសញ្ញាគឺ ចាប់ផ្តើមរលាកគល់ដំណាំក្នុងដំណាក់កាល ៥-៧ថ្ងៃ ក្រោយដុះធ្វើឲ្យរលាកជាំៗគល់ ក្រោយមកក៏ចាប់ផ្តើមដួលរលំ ហើយរីករាលដាលកាន់តែច្រើនឡើងៗលើរង កូនដំណាំ ។ លក្ខខណ្ឌគឺកូនដំណាំស្លោក ជាប់មកជាមួយគ្រាប់ដីថ្នាលសំណាបមានមេរោគ សំណើមដីខ្ពស់លើសពី ៧០% គ្មានខ្យល់អាកាស និងពន្លឺគ្រប់គ្រាន់ ។

* ជំងឺស្ងួតស្លឹកពណ៌ត្នោត: Anthrac nose

– វាបង្កឡើងដោយភ្នាក់ងារឈ្មោះ Collecto -trichum orbiculare

- រោគសញ្ញា : ដំបូងស្លឹកត្រសក់ឡើងលឿងផ្ទាំងៗធំៗក្រោយមកទៅជាស្ងួត ហើយប្រែពណ៌ទៅត្នោត ប្រផេះ ពីស្លឹកក្រោមឡើងមកលើ ធ្វើឲ្យស្លឹកដំណាំស្ងួតពីដើមមួយទៅដើមមួយ ហើយរីករាលដាលយ៉ាងរហ័ស ។

- លក្ខខណ្ឌបំផ្លាញ : នៅរដូវវស្សាភាគច្រើនជាងរដូវប្រាំង បណ្តាលមកពីសំណើមដីខ្ពស់ អាកាសធាតុក្តៅ ចន្លោះគុម្ពញឹក ចំនួនដើមក្នុងគុម្ពលើសកំណត់ពន្លឺមិនគ្រប់គ្រាន់ ខ្យល់អាកាសមិនល្អ ។

* ជំងឺរលួយឫសនិងស្ងួតបណ្តូលនៃដើម : Fusarium wilt

– វាបង្កឡើងដោយភ្នាក់ងារ ឈ្មោះ Fusarium oxysporum

– រោគសញ្ញា : ក្នុងដំណាក់កាលកូនដំណាំខ្ចីៗធ្វើឲ្យស្វិតរញមតែមិនដួលដូច Damping –Off ឡើយ។ ពេលដំណាំចំណាស់គឺ នៅពេលថ្ងៃក្តៅខ្លាំងធ្វើឲ្យរញមស្រពោន ពីមួយថ្ងៃទៅកាន់មួយថ្ងៃកាន់តែស្រពោនឡើង ៗ ដើមរបស់ដំណាំស្ងួតបណ្តូលឫសរបស់វាប្រេះហើយជាំៗ ។

- លក្ខខណ្ឌបំផ្លាញ : ជំងឺរស់នៅក្នុងដីនិងទឹក ហើយវាចម្លងពីចំការមួយទៅចំការមួយ ពីដើមមួយទៅដើមមួយដោយទឹក និងកាកសំណល់ដំណាំ អាកាសធាតុក្តៅ និងសំណើមដីខ្លាំងលើសពី ៧៥ % ងាយនិងកកើត ។

* ជំងឺក្រាម្សៅលើស្លឹក : Powdery mildew

- វាបង្កឡើងដោយភ្នាក់ងារឈ្មោះ Erysiphe cichora cearum និង phaerotheca fuligena

- រោគសញ្ញា : ដំបូងសង្កេតឃើញ លេចចេញចំណុចពណ៌លឿងតូចៗ លើស្លឹក ក្រោយមកមានស្នាមម្សៅ កញ្ចុំៗ រាងវង្វង់រយៈពេលតែ ២-៣ ថ្ងៃរង្វង់ម្សៅនេះរីករាលដាលពេញស្លឹក ទាំងស្លឹកខ្ចីក៏ដូចស្លឹកចាស់ បន្ទាប់មកបែកធ្វើឲ្យស្វិតរហុយចេញចំការ ។

- លក្ខខណ្ឌកំណើត : ច្រើននៅរដូវប្រាំង ពេលអាកាសធាតុត្រជាក់ស្ងួត មេរោគចូលចិត្តរស់នៅតាមដើម និងឈើហូបផ្លែ រដូវភ្លៀងមិនធ្វើឲ្យមានលក្ខណៈធ្ងន់ធ្ងរឡើយ ។

២- ជំងឺបង្កឡើងដោយវីរុស

- ជំងឺដែលបង្កដោយវីរុស Virus មានច្រើនប្រភេទលើដំណាំត្រសក់ដូចជា :

* ជំងឺរួញស្លឹកខ្វចុះក្រោម : Cucumber mosaic Virus

- ជំងឺប្រភេទនេះវាបង្កឡើងដោយ Mosaic Virus

- រោគសញ្ញាដំបូង វាលេចចេញចំណុចខ្លះនៅលើស្លឹក គឺសភាពរួញជាពិសេសស្លឹកខ្ចីៗ ក្នុងដំណាក់

ផ្លែពកៗក្រឡាៗ ហើយរីងនៃសំបកសាច់ត្រសក់គ្មានរស់ ជាតិ វារីកនិងរាលដាលចម្លងដោយក្រុមចៃ ។

- វិធានការការពារនិងកំចាត់ : គឺជ្រើសរើសពូជគ្មានជំងឺមេបាកំចាត់ស្មៅឲ្យស្អាត និងការពារចៃកុំឲ្យ បំផ្លាញត្រសក់ ។

* ជំងឺកោងស្លឹកទៅលើ : Squash leaf Curl

- ជំងឺនេះបង្កឡើងដោយមេរោគវីរុស Virus ដែលរស់នៅលើដើមស្លឹកល្ពៅ ហើយដែលអាចហៅថា Squash leaf Curl Birus ។

- រោគសញ្ញា : ដំបូងលេចចេញនៅលើស្លឹករដូវចំណុចពណ៌បៃតងចាស់ចំកណ្តាលស្លឹក ក្រោយមកស្លឹក នោះមិនមានសភាពត្រង់ឡើយ គឺនៅជាក្រាស់ហើយបៃតងចាស់ពេញលើផ្លែដែលកើត ក្រោយមកមានសភាពរួញៗ ផ្ទាំងៗហើយរមូរគែមស្លឹកឡើងលើហើយស្ងួតគែម ករណីដែលកើតដោយផ្លែ ធ្វើឲ្យក្តិបត្រសក់ខ្ចីៗស្វិត គួច ហើយមានពណ៌លើងវាបំផ្លាញលើប្រភេទដំណាំអំបូរត្រសក់ស្ទើរគ្រប់ប្រភេទ ។

- វិធានការការពារ និងកំចាត់ : បាញ់ថ្នាំប្រឆាំងនឹងការដុះគ្រាប់ស្មៅមុនពេលដាំដំណាំឬពូជថ្មី ឬប្រភេទដំណាំផ្សេងៗពីត្រសក់ក្នុងអំបូរ Cucurbita ceae ទុកដីចោលទំនេររយៈពេលមួយរដូវ ដាំឲ្យបានមុនរដូវរុយ ស មានវត្តមានច្រើន រួមផ្សំជាមួយវិធានការគីមីដើម្បីកំចាត់រុយ សនៅពេលវត្តមានដំបូង ។

* ជំងឺពករលោងផ្ទៃស្លឹកខាងលើ : Squash Mosaic

- ជំងឺនេះវាបង្កឡើងដោយមេរោគវីរុសឈ្មោះ Squash Mosaic Virus

- រោគសញ្ញបំផ្លាញ : ដំបូងលើកូនត្រសក់ដែលទើបនឹងចេញពិតទី ១-២ ពិនិត្យឃើញស្លឹកនោះមានស្នាម ពពាលចន្លោះសរសៃទ្រនង់ស្លឹកនៃផ្ទៃស្លឹក ហើយមានពណ៌បៃតងភ្លាវ សញ្ញាប្រហែលទៅនឹងកង្វះអាសូតដែរ ប៉ុន្តែ ត្រសក់អាចលូតលាស់បានធម្មតា ប៉ុន្តែនៅពេលត្រសក់ចេញផ្កា ស្លឹកត្រសក់លេចចេញសញ្ញាដូចធ្មេញរណានៅគែម ស្លឹក ហើយផ្ទៃស្លឹកមានសភាព ដោរៗពកៗ ផ្ទាំងហើយពណ៌បៃតងរលោងក្រាស់ នៅលើផ្លែគឺពកៗក្រឡាៗសំបកក្រាស់តែផ្លែអាចធំបង្គួរ ប៉ុន្តែក្រោយត្រសក់លែងផ្លែ ។

- ការការពារ និងកំចាត់ : គឺជ្រើសរើសពូជមេបាកុំឲ្យកើតជំងឺនេះ ប្រសិទ្ធភាពខ្ពស់ជាងគេ ។

៣- ជំងឺបង្កឡើងដោយបាក់តេរី : Verticillium Wilt

- ជំងឺនេះបង្កឡើងដោយក្រុមបាក់តេរី ដែលរស់នៅក្នុងរន្ធដី ជាពិសេសបាក់តេរី ២យ៉ាងគឺ Verti-llium dahliae និង Vertillium albo–atrum វារស់នៅគ្រប់ទីកន្លែងជាពិសេសកន្លែងដែលមានសីតុណ្ហភាពក្តៅ។

- រោគសញ្ញាបំផ្លាញ :ជំងឺនេះតែងតែរាតត្បាតលើគ្រប់ដំណាំក្នុងលំដាប់ Cucurbits សញ្ញាដំបូងលេចចេញនូវភាពរញម ស្រពោនហើយស្លឹកប្រែពណ៌ទៅលឿង ជាពិសេសស្លឹកដំបូងរបស់ដំណាំ ។ ក្រោយមកស្លឹកបែក ខាងលើទៅជាពណ៌លឿងទាំងអស់ ហើយស្ងួត ក្រោយមកដើមក៏ចាប់ផ្តើមបញ្ឈប់ការលូតលាស់ ពេលនោះសាច់ដើមចន្លោះថ្នាំងឡើងជាំៗថ្នាំងរបស់វាសភាពស្ងួត ។ កាលណាកាត់ដើមជាកង់ៗសង្កេតឃើញភាពជាំ តាមស្រទាប់ សាច់ជារង្វង់ៗក្រោយមកវាក៏ចាប់ផ្តើមត្រឡប់ទៅនៅក្នុងដីវិញ បានយ៉ាងច្រើនឆ្នាំ ។

- លក្ខខណ្ឌកកើត និងរីកសាយភាយ : ផលប៉ះពាល់យ៉ាងសំខាន់នៃការឆ្លងនិងកកើត គឺមេរោគចូលតាម រយៈឫសក្រោយមកសីតុណ្ហភាពដីប្រែប្រួលពីក្តៅទៅត្រជាក់ ឬត្រជាក់ទៅក្តៅ វាជាលក្ខខណ្ឌបង្កមួយយ៉ាងសំខាន់ ។ ជាពិសេសនៅវគ្គកំពុងចេញផ្លែព្រោះវាជ្រែកនៅក្នុងរុក្ខជាតិជុំវិញ និងដី ជាលក្ខណៈងាយនិងកើត បច្ចុប្បន្នត្រសក់ ធ្វើឲ្យមានការខូចខាតយ៉ាងច្រើននៅតំបន់ដីព្រៃខ្ពង់រាប ។

- វិធានការការពារ និងកំចាត់ : នៅប្រទេសកសិកម្មជឿនលឿនរកប្រើប្រេងពុលដែលឲ្យឈ្មោះ Soifumigation or Slar Sterilization បញ្ចូលទៅក្នុងដីទទួលប្រសិទ្ធិភាពល្អ ឬប្រើពូជធន់ទ្រាំទៅនឹងលក្ខខណ្ឌ កកើតជំងឺនេះ។

៤- សត្វល្អិតសំខាន់ៗ :

មានសត្វល្អិតចង្រៃជាច្រើនប្រភេទ ដែលបំផ្លាញដំណាំក្នុងនោះមាន សត្វល្អិតជាភ្នាក់ងារបង្ករោគ និងសត្វ ល្អិតបំផ្លាញផ្ទាល់ ។ សត្វល្អិតជាភ្នាក់ងារចំលង

 

មាន :

- ចៃបៃតង Greem peach aphid រោមជញ្ជក់ស្លឹកធ្វើឲ្យស្រស់រួញស្លឹកហើយខូចចុះក្រោម

- មមាចជញ្ជក់ស្លឹក lefaf hopper វាមានពីរប្រភេទ មាឌតូច និងមាឌធំ តែងជញ្ជក់ស្លឹក ធ្វើឲ្យស្លឹកស្រស់ស្អួតគែមហើយកោងស្លឹកឡើងលើ ។

- រុយស White fly រុយប្រភេទនេះមានមាឌតូចៗ ពណ៌ស ហើយមើលនឹងភ្នែកទទេរស្ទើរមិនឃើញ គេអាចសង្កេតវាបានត្រូវពិនិត្យមើលក្រោមស្លឹកពេលថ្ងៃក្តៅ ។

ពពួកសត្វល្អិតទាំងនោះនៅមានសត្វល្អិតបំផ្លាញផ្ទាល់ដូចជា :

- អណ្តើកមាសពណ៌លឿង Cucurbit leaf beetle វាស៊ីស្លឹកកូទីឡេដុង ត្រួយខ្ចីៗ ផ្កាញី និងផ្កាឈ្មោល វិខានដល់ការលូតលាស់យ៉ាងខ្លាំង ។

- ដង្កូវកាត់ដើម Black cutworm ដង្កូវប្រភេទនេះ ច្រើនលាក់ខ្លួននៅក្នុងដីពេលថ្ងៃ ចេញកាត់ដើមស្រស់នៅពេលយប់ លក្ខណៈបំផ្លាញក្នុងវគ្គកូនសំណាប (Young Seedling ) ។

- ដង្កូវហ្វូងស៊ីផ្លែ និងស្លឹក Beet armyworm ដង្កូវប្រភេទនេះតែងតែស៊ីស្លឹក ផ្កា ផ្លែខ្ចីៗ ធ្វើឲ្យបាត់បង់ទិន្នផលផលយ៉ាងច្រើន ព្រោះការបំផ្លាញរបស់វាលក្ខណៈជាហ្វូង ។

- ដង្កូវមូរស្លឹក Leaf folder worm វាតែងតែជ្រកលាក់ខ្លួននិងស៊ីបំផ្លាញត្រួយស្រស់ខ្ចីៗ ក្នុងវគ្គលូតលាស់ ប៉ុន្តែនៅក្នុងវគ្គបន្តពូជវាធ្វើឲ្យជួបបញ្ហាយ៉ាងខ្លាំងព្រោះវាស៊ីផ្តាច់ចង់លំអងផ្កាឈ្មោលនិងផ្កាញីនៅពេលផ្ការីក (ម៉ោង ៧-១០ព្រឹក )។

ដើម្បីការពារទៅនឹងកត្តាចង្រៃទាំងនេះគេត្រូវអនុវត្តនីវិធីសាស្ត្រច្រើនយ៉ាង ដូចជា ជ្រើសរើសរដូវផ្លាស់ប្តូរមុខដំណាំ ជ្រើសរើសពូជធន់ទ្រាំ រៀបចំដីឲ្យបានត្រឹមត្រូវ សំអាតស្មៅក្នុងចំការ ជាពិសេសគ្រប់វគ្គមានសត្វល្អិតមុនពេលវាពេញវ័យបន្ទាប់មកអនុវត្តន៍វិធានការគីមី ដើម្បីកំចាត់ ។

V. **ការប្រមូលផល** Harvesting

១-ការប្រមូលផលបន្លែ

- ការប្រមូលផលជាបន្លែគឺធ្វើឡើងក្រោយពីដាំរយៈពេលខុសគ្នា ទៅតាមប្រភេទពូជ និងអាស្រ័យទៅ និងសេចក្តីត្រូវការដូចជា :

- ពូជស្រាល : គឺគេអាចប្រមូលផលដំបូងក្រោយពីការដាំរយៈពេល ៣៥-៤០ថ្ងៃ គឺបេះផ្លែដោយយក កន្រ្តៃកាត់ត្រឹមទង នៃផ្លែហាមប្រទ្បេះយកតែផ្លែ បណ្តាលឲ្យផ្លែស្រស់ឆាប់ក្រហមប្រែពណ៌ ប្រភេទពូជនេះ ទិន្នផលមធ្យមចន្លោះពី ៨-១០តោន ១ហត ។

- ពូជកណ្តាល គឺការប្រមូលផលដំបូងក្រោយពីដាំបានរយៈពេល ៤៥-៥០ថ្ងៃ ។ ការបេះគឺកាត់យកផ្លែ ដូចជាស្រស់ទៀតដែរ ការបេះយកផ្លែស្រស់មានចំនួន ពី ៥-៧លើក ហើយទិន្នផលជាមធ្យម ១០-១២ តោន១ហត ។

- ពូជធ្ងន់ គឺធ្វើការប្រមូលផលបានច្រើនលើក ពី ៥ - ១០ លើក ហើយទិន្នផលជាមធ្យមពី ១០-១៥






 

តោន ១ហត ។

២ ការប្រមូលផលពូជ

-ដើម្បីឲ្យពូជនៅ ជំនាន់ក្រោយទទួលបាននូវភាពសុទ្ធល្អ ការជ្រើសរើសត្រូវអនុវត្តន៍ទៅតាមវិធីសាស្ត្រខាងក្រោម :

ដើមគ្មានជំងឺ និងសត្វល្អិតបំផ្លាញ ដើមលូតលាស់ធម្មតាមានលក្ខណៈតែមួយផ្នែកសំខាន់: គឺថ្ងៃខែ ចេញផ្កា ស្លឹកពណ៌និងទ្រង់ទ្រាយ ផ្លែ មានលក្ខណៈ









ដូចគ្នា ទាំងពណ៌ និងទំហំ ។

ផ្លែដែលមុនគេ (ផ្លែដំបូង) ត្រូវកាត់ចោលទុកតែផ្លែលើកទី ២ទី៣ ក្រៅពីនេះកាត់ចោល ហើយផ្លែទាំងនោះត្រូវបេះមកទុកដោយឡែកៗពីគ្នា គឺទី២ទុកដោយទី២ ទី៣ទុកដោយទី៣ នៅពេលផ្លែទុំក្រហមប្រេះបែក ក្រឡា ក្រោយពីបេះហើយត្រូវរក្សាទុកពី ៤ - ៥ ថ្ងៃ ទើបពុះផ្លែយកគ្រាប់ ត្រាំទឹកមួយយប់ បន្ទាប់មកលាងទឹកសំអាតយកគ្រាប់ដែលល្អមកដាក់ហាលថ្ងៃរយៈពេល ១-២ថ្ងៃ (ហាមហាលថ្ងៃត្រង់ និងលើកឧបករណ៍ដែក) ក្រោយមកទុកគ្រាប់ឲ្យត្រជាក់ ទើបប្រមូលយកគ្រាប់ដាក់ដប ឬកញ្ចប់ហើយបិទជិតរក្សាទុកនៅកន្លែងស្ងួត ធម្មតា ហាមត្រូវកំដៅថ្ងៃ ។

ឯកសារយោង


- Vegetable Production AVI Book
- Plant Resources of Sorth-East Asia N: 8 Indonesia 1994
- Cucurbit diseases 1988 - Petoseed
- Training Report ARC-AVRDC-1987
- Kbal Koh Station Experimental design 1996-2000